

# ពន្លឺបញ្ញា

តាំងពីសតវត្សទី១៥មក ប្រជាពលរដ្ឋខ្មែររស់ជានិច្ចនៅក្នុងគំនរទុក្ខឥតអាចគននាបាន ក្លាយខ្លួនជាប្រជាពលរដ្ឋរស់នៅក្នុងភពអន្ធភាព គ្មានស្គាល់អ្វីទៅដែលហៅថា «ពន្លឺបញ្ញា» (les lumières) ដែលជាកត្តាមួយនាំឲមនុស្សរកឃើញដោយខ្លួនឯង នូវការពិតមួយសំរាប់ខ្លួនឯង។ គេបែងចែកដាច់ នូវអារ្យធម៌ ពីពន្លឺបញ្ញា ដែលជាវត្ថុធាតុពីរ មានសារៈសំខាន់ពិតសំរាប់ភារៈនៃមនុស្ស តែមានតែពន្លឺបញ្ញាទេ ដែលជាវត្ថុធាតុទាក់ទងនឹងការពិតរបស់មនុស្ស ឯចំណែកអារ្យធម៌ គឺជាវត្ថុធាតុ សំរាប់តែចង្អុលលក្ខណៈនៃទំនៀមទម្លាប់ដ៏ល្អិតល្អន់ និងអគ្គសិល្បភាព (virtuosité) នៃសិល្បៈ ដែលមានកើតឡើងនៅក្នុងដំណើរក្នុងភាពខ្ពស់ទាប របស់នរសង្គម (société humaine) និមួយៗ។

**អ្វីទៅដែលជា«ពន្លឺបញ្ញា»? (Qu’est-ce que les Lumières ?)**

យើងដឹងថា មនុស្សម្នាក់ៗ តែងតែមានវិចារណញ្ញាណ សំរាប់យល់ដឹងអំពីសេចក្ដីពិតរបស់ខ្លួនឯង តែវិចារណញ្ញាណនេះ ជាការយល់ដឹង គ្មានការការអប់រំ (raison non éduquée) ដូចជាកូនក្មេងនោះឯង។ បើសិនជាកូនក្មេងនោះ ធំពេញវ័យ បន្តក្លាយជាមនុស្សចាស់ តែវិចារណញ្ញាណ នៅតែគ្មានការអប់រំ មនុស្សនោះ ទោះបីមានចំណាស់ប៉ុណ្ណាក៏ដោយ ក៏គាត់រស់ក្នុងចិត្តគំនិតជាកូនក្មេងជានិច្ច ដូចគ្នានឹងអ្នកចេះវិជ្ជាណាមួយ តែខ្វះវិចារណញ្ញាណមានការអប់រំ ការចេះវិជ្ជានោះមិនទុកជា ពន្លឺបញ្ញា នោះដែរ ដូចមនុស្សចេះអានអក្សរ តែឥតយល់ន័យអ្វីបន្តិចនៃអត្ថបទទាំងមូល។

ក្នុងន័យនេះឯង ដែលគេអាចយកមកបញ្ជាក់បានថា «អប់រំវិចារណញ្ញាណ» គឺជាការបញ្ចេញឲឃើញ (révélation) ជាដំបូង នូវអត្ថិភាព នៃវិចារណញ្ញាណដែលមាននៅក្នុងភារៈពីកំណើត

នៃមនុស្សមក តែសច្ចៈ នៃអំណាចញាណ (pouvoir de compréhension) នៃវិចារណញ្ញាណនេះ កើតមានឡើង ពីការអប់រំ។ ការបញ្ចេញឲយើញកើតមានមកពីការអប់រំ ដែលជាអ្នកដឹកនាំវិចារណញ្ញាណរបស់ខ្លួនឲយល់ដឹងអំពីអំណាច របស់វា ហើយបន្ទាប់មកនាំឲវាយល់ដឹងដោយខ្លួនឯងមួយរំពេច នូវការបញ្ចេញឲឃើញនេះឯង។ ពន្លឺបញ្ញា ជាការអំរំ នៃវិចារណញ្ញាណ សំរាប់ខ្លួនឯង ដែលគេហៅថា «វិចារណញ្ញាណភ្លឺស្វាង»។ វិចារញ្ញាណនេះលែងត្រូវការ នូវការបញ្ចេញឲឃើញពីខាងក្រៅ និងការចាប់អារម្មណខាងផ្លូវចិត្ត ព្រោះវាមានអំណាចខ្លួនឯង ដើម្បីទាក់ទងដោយខ្លួនឯង ជាមួយសច្ចៈសតិ(les vérités spirituelles)។

ពន្លឺបញ្ញាជា គំនិតប្រកបទៅដោយវិចារណញ្ញាណ (le penser rationnel) របស់ជីវិតមនុស្ស ដែលមានឥទ្ធិពលសំខាន់មកលើកិរិយា និង ទីដែលសំដៅទៅ (destination) របស់ខ្លួន។ គេអាចនិយាយបានដែរថា ពន្លឺបញ្ញានេះ នាំឲខ្លួនជាអ្នកទទួលខុសត្រូវលើខ្លួនឯង ដូចគ្នានឹងអនុសាសន៍របស់ព្រះពុទ្ធថា «ខ្លួនទីពឹងខ្លួន»។ មានការយល់ដឹងដោយខ្លួនឯង គឺស្គាល់ខ្លួនឯងពិត មិនចាំបាច់ត្រូវការជំនួយពីខាងក្រៅ សំរាប់យល់ដឹងអំពីអ្វីដែលខ្លួនត្រូវធ្វើ ដើម្បីឲបានសំរេចនូវគោលបំណងរបស់ខ្លួនចង់បាន ដែលយើងហៅថាភាវៈនៃពន្លឺបញ្ញា។

**១. ភាវៈនៃពន្លឺបញ្ញា (État des Lumières) នៃប្រជាជាតិខ្មែរ**

មូលដ្ឋាននៃពន្លឺបញ្ញាខ្មែរតាំងពីបូរាណកាលមក គឺកើតចេញពីសិក្ខាបទនៃសាសនា (ព្រហ្មញ្ញសាសនា និង ពុទ្ធសាសនា) ឯចំណែកជំនឿអាយ (ជំនឿដើមរបស់ខ្មែរ) ជាទំនៀមទំនាប់សំរាប់ការរស់នៅជាធម្មតានៃជនជាតិខ្មែរ ដែលគេអាចទុកវាជាបុព្វអារ្យធម៌ខ្មែរ។ បើនិយាយឲស្រួលយល់ គឺគេអាចទុក ទំនៀមទំនាប់ ជារាងកាយ (corps) នៃសង្គមខ្មែរ ឯចំណែកពន្លឺបញ្ញាជាគំនិតប្រកបទៅដោយវិចារណញ្ញាណ នៃមនុស្សខ្មែរ។

**អ្វីជាបញ្ញា (entendement)?**

តាមការពន្យល់របស់ព្រះមានព្រះភាគ (ព្រះពុទ្ធ) ៖ «*ពាក្យបញ្ញាគឺបានខាងប្រាជ្ញា ការដឹងច្បាស់ ការពិចារណាការពិចារណាឃើញ ការកំណត់ ការកំណត់ដឹង ការកំនត់ដឹងសព្វ ភាពនៃការឈ្លាសវៃ ភាពនៃការវៀងវៃ ភាពនៃបញ្ញាដ៏ពេញលេញ សេចក្តីយល់ច្បាស់ ការគិតការ*

*រំពឹង ប្រាជ្ញាក្រាស់ ប្រាជ្ញាសំរាប់ទំលាយបង់នូវកិលេស ប្រាជ្ញាសំរាប់ដឹកនាំ ប្រាជ្ញាសំរាប់ឃើញច្បាស់ សេចក្តីដឹងច្បាស់សភាពនៃការទំលុះបញ្ញា ឥន្ទ្រិយគឺបញ្ញាកម្លាំងប្រាជ្ញា សស្ត្រាគឺបញ្ញា ប្រាសាទគឺបញ្ញា ពន្លឺបញ្ញារស្មីបញ្ញា ការរុងរឿងបញ្ញាកែវបញ្ញា សេចក្តីមិនវង្វេង ការពិចារណាធម៌ សេចក្តីយល់ត្រូវ*»។

ឯចំណែកការយល់ឃើញរបស់ព្រហ្មញ្ញសាសនាវិញ បញ្ញា គឺអាទិទេព ដែលគេហៅថា បញ្ញាព្រះដែលជាបុព្វព្រះ (Brahmâ et Incrée) ជាព្រះមានលក្ខណៈព្រមគ្នាជា «ជិវិត» ផង ជា «បុគ្គលនិរជីវិត»(បុគ្គលឥតជីវិត) ជាវត្ថុផង ជា«អ្នកបង្កើត» ផង ជាការ «ការបង្កើត» ផង។ បញ្ញាព្រះជានិមិត្តរូប នៃច្បាប់លោកធាតុផង (ordre du cosmo) និងសុខដុមរបស់លោកធាតុផង ដែលកើតមានឡើង ពីការធ្វើបូជាគ្រប់បែបយ៉ាង និងជា វិតីវាចា (parole rituel) របស់ព្រះអង្គ។

ដូចយើងបានដឹងថា នរសង្គមខ្មែរ បានទទួលការអប់រំ ពីព្រហ្មញ្ញសាសនាផង និង ពុទ្ធសាសនាផង នាំវិចារណញ្ញាណអប់រំខ្មែរ ឬ ពន្លឺបញ្ញាខ្មែរ មានការលាយឡំ រវាងទស្សនៈ «ខ្លួនទីពឹងខ្លួន»ជាមួយនិង ទស្សនៈ «មនុស្សទីពឹងអាទីទេព»។ តែយើងដឹងថា ទស្សនៈ មនុស្សទីពឹងអាទីទេព មានឥទ្ធិពលខ្លាំងក្នុងនរសង្គមខ្មែរ ព្រោះទស្សនៈនេះ ត្រូវបានអ្នកដឹងនាំខ្មែរ ឬ មហាក្សត្យខ្មែរ ចាប់យកមកធ្វើជាទស្សនៈដឹកនាំជាតិ ព្រោះខ្លួនតាំងខ្លួនជាអាទិទេពក្នុងឋានមនុស្សលោក ដូច្នេះប្រជាពលរដ្ឋ រស់នៅក្នុងសេចក្តីរំពឹងជានិច្ចលើអ្នកដឹកនាំដើម្បីរស់ក្នុងនិរទុក្ខ (គ្មានទុក្ខ)។ ឯចំណែកទស្សនៈ «ខ្លួនទីពឹងខ្លួន» ត្រូវអ្នកដឹកនាំ យកមកធ្វើការបកស្រាយ ចងក្រងជាទ្រឹស្តី ឲវាមានលក្ខណៈត្រឹមតែ ការរកសេចក្តីសុខសំរាប់តែអាត្មាអញតែប៉ុណ្ណោះ។

រួមសេចក្តីមក គឺថាទស្សនៈ ទីពឹងអាទីទេព ឬ អ្នកដឹកនាំ សំរាប់សេចក្តីសុខ នៃនរសង្គមខុសអំពីទស្សនៈ ខ្លួនទីពឹងខ្លួន សំរាប់សេចក្តីសុខបុគ្គល។ ការបញ្ជោក (imprégnation) នៃគំនិតនេះនៅក្នុងសង្គមខ្មែរ នាំឲខ្មែរម្នាក់ៗ ចែកដាច់ ខ្លួនជាបុគ្គល ពី សង្គមនយោបាយមានន័យថា អ្វីជាកិច្ចការសាធារណៈ គឺអ្នកដឹកនាំជាអ្នកសំរេច ឯចំណែក អ្វីដែលជាកិច្ចការផ្ទាល់ខ្លួន គឺខ្លួនត្រូវទីពឹងខ្លួនឯង។ ដូច្នេះឯង អ្វីដែលជាប្រយោជន៏សាធារណៈ មិនពិតជាវានាំមកនូវសេចក្តីសុខដល់បុគ្គលនោះឡើយ។ ហេតុនេះឯង របបសាធារណៈរដ្ឋ មិនសុទ្ធជារបប

ស្វែងរកសុភមង្គលដល់បុគ្គលនោះឡើយ ដូចយ៉ាងរបបសាធារណរដ្ឋសង្គមនិយមក្ដី ប្រជាធិបតេយ្យក្ដី ជារបបការពារប្រយោជន៍រដ្ឋ មិនមែនជារបបការពារប្រយោជន៍មនុស្សនោះទេ។ សាធារណរដ្ឋបែបនេះ គេទុកជារបបអត្តាវសនិយម (despotisme) ដែលជារបបសាធារណរដ្ឋផ្អែកលើកម្លាំងទិដ្ឋិ (forces dogmatiques) ហើយបដិសេធកម្លាំងរិះគន់។ ជារបបដឹកនាំបង្កើតតាមការបង្ខំឲមានកម្លាំងគោរពប្រតិបត្តន៍ ធ្វើគ្រប់បែបយ៉ាងឲប្រជាពលរដ្ឋរស់នៅក្នុងភាពខ្ជិលច្រអូស និងភាពកំសាក គិតពិចារណាអំពីកិច្ចការសាធារណ: ឬ គិតស្វែងរកប្រយោជន៍រួម។ រួមសេចក្ដីមក របបសាធារណរដ្ឋសង្គមនិយម ឬ ប្រជាធិបតេយ្យ ជារបបដែលប្រជាពលរដ្ឋមានសេរីភាពក្នុងទ្រង់បញ្ញារដ្ឋ (entendement de l'Etat) ហើយការទាមទារសេរីភាពណាដែលហួសពីបញ្ញារដ្ឋ ត្រូវអ្នកដឹកនាំគេទុកជាសេរីភាពខ្វែងមតិ (liberté dissidente)។ សាធារណរដ្ឋបែបនេះ ខុសពីសាធារណរដ្ឋសេរី ដែលទុកលទ្ធិប្រជាធិបតេយ្យសេរី ជាគ្រិះនៃរបបដឹកនាំ។ លទ្ធិប្រជាធិបតេយ្យសេរី ជាអានុភាពនៃច្បាប់ ដែលកើតចេញពីឆន្ទ:ប្រជាពលរដ្ឋដែលជាច្បាប់សំរាប់ការពារប្រយោជន៍សាធារណ:ផង និង ប្រយោជន៍បុគ្គលផង។ នៅក្នុងរបបនេះ គេអាចនិយាយបានថា សាធារណជន បំភ្លឺដោយខ្លួនឯង ដែលជាពន្លឺបញ្ញា សំរាប់ដឹងយល់ច្បាស់អំពីអំណាចរបស់ខ្លួន ដែលជាបញ្ញាដឹកនាំប្រាជ្ញា សំរាប់ឲឃើញច្បាស់ពិតនូវប្រយោជន៍ជាតិ ព្រោះប្រយោជន៍ជាតិ ជាប្រយោជន៍សាធារណ:ផង និង ជាប្រយោជន៍ពលរដ្ឋផង។ ពន្លឺបញ្ញានេះ ជាគ្រឿងសំរាប់រំលត់នូវអវិជ្ជា និង កំចាត់នូវភាពខ្ជិលច្រអូស និង ភាពកំសាក ក្នុងការស្វែងរកប្រយោជន៍ជាតិ។ ឆន្ទ:រួមរបស់ប្រជាជន បង្កើត ជាប្រជាពលរដ្ឋ នៃលទ្ធិប្រជាធិបតេយ្យដែលពលរដ្ឋម្នាក់ៗ មានអារម្មណ៍ថាខ្លួនជាសមាជិក នៃប្រជាជាតិ ដែលជាអាទិករកសាងអធិបតីដ៏ល្អប្រសើរសំរាប់ខ្លួន ក៏ដូចជាប្រយោជន៍រួម ក្នុងសេចក្ដីសង្ឃឹមនឹងអាចឲវាកាត់តែមានសុក្រិតភាព នៃសីលធម៌ ក្នុងសង្គមជាតិ។

**២. ភូមិសាសនា (Domaine de la religion)**

ខ្មែរអធុនិក (ខ្មែរក្នុងជាន់ឥឡូវ)[1] កំពុងរស់ក្នុងស្ថានភាពបូកឡុក រវាងមរិចិកា[2] (ការភាន់

[1] អធុនិក=contemporain។

[2] មរិចិកា=mirage។

ភ្នែក) នៃអភិវឌ្ឍន៍ជាសប្បនិម្មិត ជាមួយនឹងមហាទុក្ខ។ តែដោយសារមានទម្លាប់រស់ក្នុង «បញ្ញានៃអ្នកដឹកនាំ» ឬ «ទីពឹងអ្នកដឹកនាំ» ក៏នាំគ្នាអនុមាន (ហេតុស្មានយក) ថាស្ថានភាពនេះ ជាវិការ (ការផ្លាស់ប្តូរ) ជាភាពធម្មតា ជាធម្មជាតិ របស់មនុស្ស ដែលជាសត្វលោករស់ក្នុងធម៌ «អាទិទេពជាទីរំពឹង» និង «កម្មផល»។ មរិចិកា នៃរមណីយដ្ឋាន និង នរកទុក្ខដ្ឋាន ជាភព ឬ លោកនេះ សំរាប់មនុស្សមកកើតរស់នៅ ដើម្បីទទួលនូវផលដែលខ្លួនបានកសាងពីជាតិមុន ឬ ត្រូវរំពឹងលើអាទិទេព។

**តាមធម៌នៃពុទ្ធសាសនា** សេចក្តីសុខ និង ទុក្ខ របស់មនុស្សនៅក្នុងលោកនេះ ជាកុសលនៅក្នុងវាលវែងវង្គសង្សារនៃបរិយត្តិធម៌ (រៀនសូត្រឲចេះដឹង) និង បដិបត្តិធម៌ (ចេះដឹង រួចត្រូវប្រតិបត្តតាមធម៌) ដើម្បីរកនិរាមិសសុខ (សុខក្នុងលោកនេះផង និង សុខនៅក្នុងបរលោកផង) ដែលព្រះមានព្រះភាគទុកជាថ្នាក់បដិវេធ (គឺដឹងច្បាស់ចាក់ធ្លុះនូវធម៌ដែលរំលត់ទុក្ខកិលេស)។ ការអន្ទោលស្លាប់កើត ជាផ្លូវ នៃភ័ព្វសំណាងថ្មី ឬ ផ្លូវ នៃសុក្រិតភាព សំរាប់មនុស្សដើម្បីស្វែងរកនិរាមិសសុខនេះ។

តាមធម៌នេះ គេអាចសន្និដ្ឋានបានថា «មរណៈភាព ជាជីវិតថ្មីសំរាប់សេចក្តីសង្ឃឹមរបស់មនុស្ស» ក្នុងកំណើតថ្មី ដែលព្រលឹងនាំយកមកជាមួយនូវសម្បត្តិសុខ និង ទុក្ខ (កម្មផល) ដែលវាកើតឡើងពីអំពើ ដែលខ្លួនបានសាបព្រោះនៅក្នុងគ្រប់អតិតកាលជាតិ។ សម្បត្តិនេះមាននៅក្នុងសតិ ដើម្បីឲបញ្ញាកើតឡើងដឹង ឲសតិកើតរលឹកសិក្សាពិចារណាបន្តសិក្សាព្រះធម៌ដ៏ល្អិតសុខុមជ្រៅ ឲបានយល់យ៉ាងត្រឹមត្រូវ ក្នុងសុច្ឆន្ទៈ (បំណងល្អ) ដើម្បើរកនិព្វានក្នុងភពនវិទុក្ខ (ភពឥតទុក្ខ)។ ក្នុងគោលបំណងល្អនេះ គឺជា «ទឹកធម៌» សំរាប់លាងសំអាតកិរិយានិង សតិ អាចបំលាស់ប្តូរ ទុរជនឲក្លាយជាសុជន ព្រោះមនុស្សម្នាក់ៗមានធាតុនៅក្នុងអាត្មន ជាមនុស្ស, អមនុស្ស និង តិរច្ឆាន។ ដូច្នេះបើគ្មានពន្លឺបញ្ញា ឬ មានធម៌ សំរាប់ការអប់រំចំរើននៃសតិ ឬ អប់រំវិចារណញ្ញាណ នោះទេ គឺមនុស្ស ពុំអាចមានលក្ខណៈជាមនុស្សបាននោះទេ។

ក្នុងគោលបំណងល្អនេះឯង នាំឲមនុស្សម្នាក់ៗ ដើរលើផ្លូវសុក្រិតភាព ឬ បារមីធម៌ (état de perfection) សំរាប់ខ្លួនឯង ដើម្បីរស់ជាសុជន ដែលតម្រូវឲមានលក្ខណៈ បួនយ៉ាងជាមូល គឺៈ

យល់ត្រូវ, ត្រិះត្រូវ, និយាយត្រូវ និងការងារត្រូវ ដែលផ្ទុយស្រឡះពី៖ អវិជ្ជា, រាគៈ (désir), មានះ និង បដិឃៈ (haine)។ លក្ខណៈបួនយ៉ាងជាមូល នៃមនុស្សនេះឯង ដែលខ្មែរយើងហៅថា**សីល** (conduite éthique) ឬ មនុស្សមានទេវតា ឬ មានពិត។ រួមសេចក្តីមក សេចក្តីសង្ឃឹមរបស់មនុស្ស គឺសំរាប់ការអប់រំចំរើនចិត្ត តាមផ្លូវបារមីធម៌ ហើយសង្ឃឹមនេះអាចមានកើតបាន តាមការអប់រំវិចារណញ្ញាណ មានថ្នាក់បី៖ ១. ការសិក្សាធម៌ (បរិយត្តិ), ២. អនុវត្តន៍ធម៌ ដើម្បីសំរេចនូវធម៌ដែលរំលត់កិលេសរំលត់ទុក្ខ (បដិបត្តិ), ៣. ដឹងច្បាស់ចាក់ធ្លុះនូវគោលបំណងនៃធម៌ គឺរំលត់ទុក្ខ (បដិវេធ)។ ការអប់រំចិត្តនេះ គឺធ្វើបានដោយខ្លួនឯង និង ខ្លួនទីពឹងខ្លួន តាមគោលវិធីធ្វើសង្ខារ (formation) ចិត្ត ឬ វិធីទូន្មានចិត្ត (យោគៈ), តាមការអនុវត្តន៍ ឬ វិធីទូន្មានកាយ (គមធម៌) ជារូបសកម្មភាព (បដិបទា) ក្នុងជំនឿមានហេតុផល ដើម្បីឲសំរេចបាននូវសេចក្តីប្តេជ្ញា (កតិកា) ឲខ្លួនក្លាយជាមនុស្សពិត រស់ជាសុជាជន (ជនមានកំណើតល្អ) នៅក្នុងសង្គមជាតិ។

**៣. ភូមិនយោបាយ (Domaine de la politique)**

សុជននេះ គឺគ្មានអ្វីក្រៅពី «ពលរដ្ឋ» (citoyen) នោះឡើយ ដែលជានីតិបុគ្គលផង និងជា នីតិជនផង គឺមានសទ្ធិ និង ករណីយកិច្ចក្នុងឋានៈខ្លួនជាពលរដ្ឋ។

បើយក សុជន មកប្រដូចនឹង ពលរដ្ឋ គឺត្រូវឈានជំហានចូលទៅក្នុងភូមិនយោបាយ។ សួរថា តើពន្លឺបញ្ញា ជាអ្វីនៅក្នុងភូមិនយោបាយ?

ពន្លឺបញ្ញា គឺការយល់ដឹងអំពីតួនាទីរបស់ខ្លួន ក្នុងឋានៈខ្លួនជាពលរដ្ឋ។ ការយល់ដឹងនេះ គឺកើតមានឡើងពីការទទួលការអប់រំ។ ពលរដ្ឋដែលបានទទួលការអប់រំ ជាវរៈជន (និយមន័យទូលាយ) ជាសុជនមានវប្បធម៌ជាពលរដ្ឋ (culture civique) និងចេះទទួលខុសត្រូវលើអំពីរបស់ខ្លួនដែលខ្លួនបានប្រព្រឹត្ត។ កម្រងនៃវប្បធម៌ពលរដ្ឋ មាននៅក្នុងលទ្ធិប្រជាធិបតេយ្យតាមផ្លូវនយោបាយ និង លទ្ធិប្រជាធិបតេយ្យតាមផ្លូវសង្គម។

**-លទ្ធិប្រជាធិបតេយ្យតាមផ្លូវនយោបាយ** ៖ គឺភាគកម្ម (participation) ជាសកម្ម នៃគ្រប់សកម្មភាពនយោបាយ។ នយោបាយជាកិច្ចការរបស់ប្រជាពលរដ្ឋ ពុំមែនជាកិច្ចការរបស់អ្នក

ដឹកនាំនោះឡើយ។ អ្នកដឹកនាំ ដែលជាដំណាង នៃប្រជាពលរដ្ឋ គ្រាន់តែមានតួនាទី យកឆន្ទៈប្រជាធិបតី មកអនុវត្ត ដើម្បីធ្វើឲសម្រេចនូវគោលបំណងដែលប្រជាពលរដ្ឋចង់បាន។ នយោបាយវិទូ (politologue) ឲឈ្មោះអ្នកដឹកនាំនយោបាយជាតិ ថា«អ្នកដឹកនាំនយោបាយ» (gouvernants) ខុសពីនិយមន័យ «អ្នកដឹកនាំ» ដែលគេសំដៅទៅលើគ្រប់បុគ្គលណា ទទួលបន្ទុកអំណាច នៅក្នុងអង្គាឯកជនណាមួយ (មិត្តសមាគម, សហគ្រាស, សហជីព, គណបក្សនយោបាយ)។ ប្រជាពលរដ្ឋជាអ្នកជ្រើសរើសអ្នកដឹកនាំនយោបាយដូច្នេះពលរដ្ឋនិមួយៗ ត្រូវមានការយល់ដឹងអំពីនយោបាយ ដើម្បីបំពេញករណីយកិច្ចខ្លួនជាពលរដ្ឋ។ ករណីកិច្ចឈរនៅលើសំណួរបីយ៉ាងៈ ហេតុអ្វីត្រូវជ្រើសរើសអ្នកដឹកនាំនយោបាយ? ត្រូវជ្រើសរើសបែបណា? តើត្រូវជ្រើរើសយកអ្នកណា?
ដើម្បីឆ្លើយបាននូវសំណួរបីយ៉ាងនេះ ពលរដ្ឋត្រូវមានការយល់ដឹងនូវគោលបំណងខ្លួនឲច្បាស់ ដែលវាភ្ជាប់ជាចាំបាច់ទៅនឹងប្រយោជន៏ជាតិ, ប្រយោជន៏ប្រជាពលរដ្ឋ និង ប្រយោជន៏ឯកជន។ ប្រយោជន៏ទាំងបីនេះ មានច្បាប់ពីរសំរាប់គ្រប់គ្រង គឺច្បាប់លាយលក្សអក្សរ (loi écrite) និង បវេណី (coutume)។ ប្រជាពលរដ្ឋជាអ្នកទទួលខុសត្រូវ លើជម្រើសរបស់ខ្លួន ព្រោះខ្លួនជាម្ចាស់អំណាច។ រួមសេចក្ដីមក ភាគកម្ម និង ការទទួលខុសត្រូវ ជាសារជាតិនៃពលរដ្ឋ ក្នុងសកម្មភាពនយោបាយជាតិ។ បើប្រជាពលរដ្ឋមិនជួយខ្លួនឯង ដោយខ្លួនឯក ដើម្បីខ្លួនឯង គឺ អត្ថិភាពខ្លួនថិតនៅក្នុងភារៈនៃធម្មជាតិ ហើយខ្វះសុភមគ្គល ដែលនាំឲខ្លួនរស់ជានិច្ចនៅក្រៅសង្គមនយោបាយ គឺបន្តរស់តាមតែទំនៀមទម្លាប់ ដែលវាគ្មានពន្លឺបញ្ញាអ្វីនោះឡើយ។ រស់នៅក្នុងសង្គមនយោបាយ ត្រូវចាំបាច់មានការអប់រំនយោបាយ ដែលគេអាចឲឈ្មោះបានថា «ប្រជាការអប់រំ» (éducation démocratique) ជាការអប់រំដើម្បីឲបុគ្គល ក្លាយជាពលរដ្ឋ ដែលជាបុគ្គលអាចមានលទ្ធភាព កសាងខ្លួនឯង ដោយខ្លួន ឲខ្លួនឯងទៅជាបុគ្គលស្វយ័តក្នុងសេចក្ដីសម្រេចអ្វីមួយ។

**-លទ្ធិប្រជាធិបតេយ្យតាមផ្លូវសង្គម** ៖ គឺជាការបង្រៀនបន្តៗគ្នា នៃកម្រងការចេះដឹង ដែលមាននៅក្នុងអារ្យសង្គម (société civilisée) តាមការសិក្សា (instruction)។ ការសិក្សាជាសកម្មភាពនៃសង្គម ដែលមានអ្នកទទួលបន្ទុក បង្រៀននូវគ្រប់វិជ្ជាសង្គម (savoir social) ដូចជា

វិទ្យាវិជ្ជា, ចំណេះប្រកបដោយវិចារណញ្ញាណ, សាសនា, ប្រពៃណី, រឿងព្រេងចេញពីប្រជាប្រកពក្តី។ វិជ្ជាសង្គម ជាចំណែកមួយ នៃការចេះដឹងរបស់បុគ្គលនិមួយៗ ដែលជាសមាជិកនៃសង្គម។ ការសិក្សានូវវិជ្ជាសង្គមនេះ ត្រូវធ្វើឡើង ក្នុងគោលដៅ ឲយល់ដឹងច្បាស់អំពីគ្រឹះនៃវិជ្ជាសង្គម សំរាប់លុបបំបាត់ចំណេះ ឬ ជំនឿឥតហេតុផល ដែលជាចំណោះ ឬ ជំនឿដែលជាឧបសគ្គ សំរាប់ធ្វើឲល្វូតលាស់នៃពន្លឺបញ្ញានៃពលរដ្ឋ, បង្កើនកំពស់ការសិក្សាគ្រប់វិស័យនៃប្រជាពលរដ្ឋ សំរាប់ជាមធ្យោបាយចិញ្ចឹមជីវិត និង ការលើកកំពស់ជីវភាព (promotion sociale)។ ប្រជាការអប់រំ និង ការសិក្សាវិជ្ជាសង្គម ត្រូវធ្វើឡើងស្របគ្នា ទើបមានសមតាក្នុងសង្គមនយោបាយបាន។ គេពុំអាចយកលទ្ធិប្រជាធិបតេយ្យសេរីមកអនុវត្តនៅក្នុងសង្គមមួយ ដែលកំពស់ការសិក្សាវិជ្ជាសង្គម នៃប្រជាពលរដ្ឋ នៅទាបបំផុតបាននោះឡើយ តែអ្នកដឹកនាំនយោបាយ ក៏ពុំអាចបំបិទសេរីភាពពលរដ្ឋ បានយូរនោះដែរ នៅក្នុងសង្គមមួយ ដែលកំពស់ការសិក្សាវិជ្ជាសង្គមនិង ប្រជាអប់រំ ប្រជាពលរដ្ឋមានកំរិតខ្ពស់នោះដែរ។

**សេចក្តីសន្និដ្ឋាន**

ពន្លឺបញ្ញា នៃពលរដ្ឋ កើតមានបានពី ធម្មជាតិ, ការសិក្សានៃវិជ្ជាសង្គម និង ប្រជាអប់រំ។ បុគ្គលនិមួយៗ មានការវិវឌ្ឍន៍ជានិច្ចក្នុងជីវិតរបស់ខ្លួន គឺ ពីកូនង៉ែត មកដល់ពេញវ័យ ឆ្លងកាត់គ្រប់ដំណាក់កាលនៃជីវិតរបស់មនុស្ស។ បុគ្គលនយោបាយ ឬ ពលរដ្ឋ ជាទីដែលគេសំដៅទៅដើម្បីឲខ្លួនក្លាយជាម្ចាស់ នៃវាសនារបស់ខ្លួន សំរាប់រស់ឲមាន និរន្តរាយ, វិបុលភាព, សេរីភាព និង សុភមង្គល។ បំណងបីយ៉ាង និរន្តរាយ, វិបុលភាព, សេរីភាព វាមានលក្ខន្តិកៈ ជាតម្លៃនៃលទ្ធិប្រជាធិបតេយ្យ ដូច្នេះ អ្វីជាសញ្ញាណ (notion) នៃតម្លៃ គឺជា ឧត្តមគតិ (idéal) ដែលបុគ្គលនិមួយៗ តែងចង់បាន តែលទ្ធិប្រជាធិបតេយ្យមិនអាចធានារកជូន ឧត្តមគតិនេះបាននោះឡើយ ប៉ុន្តែតែ លទ្ធិប្រជាធិបតេយ្យ អាចធានាឲតម្លៃនេះមាននៅក្នុងការអនុវត្តន៍របស់ខ្លួនជានិច្ច ដើម្បីឲបុគ្គលនិមួយៗ មានមធ្យោបាយ ទៅតាម លទ្ធភាពរបស់ខ្លួនរាងៗខ្លួន នៃការស្វែងរកសុភមង្គលក្នុងឧត្តមគតិដែលខ្លួនចង់បាន។ នៅក្នុងលទ្ធិប្រជាធិបតេយ្យ ការស្វែងរកសុភមង្គល មិនមែនដូចស្វែងរកកំណប់ទ្រព្យនោះឡើយ ព្រោះសុភមង្គលជាផលិកម្មរួម ដែលបុគ្គលម្នាក់ៗរួមគ្នាបង្កើតឡើង ដើម្បីខ្លួនឯង នៅក្នុងដែនឯកជន (sphère

privé) និង ដើម្បីជាសុភមង្គលរួមនៅក្នុងដែនសាធារណៈ។ ក្នុងន័យនេះ គេអាចនិយាយបានថា «សិទ្ធិសុភមង្គល» គឺជាសិទ្ធិ មានការលាយឡំជាមួយនឹង សិទ្ធិរបស់បុគ្គលម្នាក់ៗ មានសិទ្ធរក្សាសុភមង្គលខ្លួន។ ពន្លឺបញ្ញា ដែលកើតមានពីធម្មជាតិ, ការសិក្សានៃវិជ្ជាសង្គម និង ប្រជាអប់រំ ជាអ្នកអភិបាលលើតណ្ហានៃបុគ្គលម្នាក់ៗដែលអាចនាំបំផ្លាញសុភមង្គល ដែលជាដំណាក់ចុងក្រោយនៃលទ្ធិប្រជាធិបតេយ្យ។ បុគ្គលមានពន្លឺបញ្ញា គឺជាពលរដ្ឋ ហើយពលរដ្ឋម្នាក់ត្រូវមានសីលធម៌ (vertu)  ដែលមានលក្ខណៈគ្រិះ៥យ៉ាង៖ ភាគកម្ម ជាសកម្មក្នុងកិច្ចការសាធារណៈ, មានការអប់រំនយោបាយ, មានការសិក្សាវិជ្ជាសង្គម និង ខ្លួនទីពឹងខ្លួន។ ត្រូវដឹងថាសីលធម៌ មិនអាចមានជានិច្ចនោះឡើយ ត្រូវចាំបាច់បង្កើតវានៅគ្រប់ពេលវេលា ដើម្បីប្រយុទ្ធ ឲមានជ័យជំនះជាថ្មី ទៅលើអត្តទត្តភាព នៃតណ្ហារបស់បុគ្គលម្នាក់ៗ ដែលវាតែងតែមានជាថ្មីនោះដែរ៕

**សង្ហា ឧប**

ថ្ងៃទី១០កក្កដា ឆ្នាំ២០១៤